ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ៣៥ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសម្រេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

ក

មាតិកា

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៩-៧-១៩៩៦	ក្រឹត្យ ជស.រកត ០៧៩៦/៣៦ តែងតាំងឯកឧត្តម សារ៉ាក់ ខាន់ អគ្គនាយកក្រសួងសេដ្ឋកិច្ច និងហិរញ្ញកិច្ច ជាទីប្រឹក្សាផ្ទាល់របស់ សម្តេច ជា ស៊ីម	១៥០៩
១៤-៩-១៩៩៦	ព្រះរាជក្រឹត្យ នស/រកត/០៩៩៦/៦៩ តែងតាំងឯកឧត្តម ស ខេង ជាឧកញ៉ា	១៥១០
១៤-៩-១៩៩៦	ព្រះរាជក្រឹត្យ នស/រកត/០៩៩៦/៧០ តែងតាំងឯកឧត្តម ឯម សំអាន ជាឧកញ៉ា	១៥១១
១៤-៩-១៩៩៦	ព្រះរាជក្រឹត្យ នស/រកត/០៩៩៦/៧១ តែងតាំងឯកឧត្តម គន់ គីម ជាឧកញ៉ា	១៥១២
១៤-៩-១៩៩៦	ព្រះរាជក្រឹត្យ នស/រកត/០៩៩៦/៧២ លើកលែងទោសអោយ លោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការ បរទេស ក្នុងរដ្ឋាភិបាលនៃប្រទេសកម្ពុជាប្រជាធិបតេយ្យ	១៥១៣

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

១៦-៩-១៩៩៦	អនុក្រឹត្យលេខ ១៧១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៥១៤
១៦-៩-១៩៩៦	អនុក្រឹត្យលេខ ១៧២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៥១៥
១៦-៩-១៩៩៦	អនុក្រឹត្យលេខ១៧៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៥១៦
១៦-៩-១៩៩៦	អនុក្រឹត្យលេខ ១៧៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៥១៨
១៦-៩-១៩៩៦	អនុក្រឹត្យលេខ ១៧៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៥១៩

១៦-៩-១៩៩៦	អនុក្រឹត្យលេខ ១៧៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១៥២១
១៦-៩-១៩៩៦	អនុក្រឹត្យលេខ ១៧៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១៥២៣
១៦-៩-១៩៩៦	អនុក្រឹត្យលេខ ១៧៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១៥២៤
១៦-៩-១៩៩៦	អនុក្រឹត្យលេខ ១៧៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១៥២៥
២០-៩-១៩៩៦	អនុក្រឹត្យលេខ ១៨០ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ	១៥២៦
២៣-៩-១៩៩៦	អនុក្រឹត្យលេខ ១៨១ អនក្រ.តត ស្ដីពីការផ្ទេរភារកិច្ចនាយទាហាន នៃ កងយោធពលខេមរភូមិន្ទ	១៥២៧

២ - សេចក្ដីសំរេច

១៧-៩-១៩៩៦	សេចក្ដីសំរេចលេខ ៣៩ សសរ ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួង សំរាប់រៀបចំពិធីបុណ្យខួបអនុស្សាវរីយ៍ ៥ ឆ្នាំ លើកទី ១ នៃទិវាកិច្ចព្រមព្រៀងសន្តិភាពកម្ពុជា នៅទីក្រុងប៉ារីស	១៥២៨

៣ - សារាចរណែនាំ

២៣-៩-១៩៩៦	សារាចរណែនាំលេខ ០៥ ស.រ.ណ.ន ស្ដីពីការរៀបចំខួបអនុស្សាវរីយ៍លើកទី ៥ នៃទិវាចុះហត្ថលេខាលើកិច្ចព្រមព្រៀងដើម្បីសន្តិភាពកម្ពុជា នាទីក្រុងប៉ារីស ២៣ - ១០ - ១៩៩៣ - ២៣ -១០ - ១៩៩៦	១៥៣១

III - ការងារបណ្ដាក្រសួង

ប្រកាសអន្តរក្រសួង

១ - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

១៩-៩-១៩៩៦	ប្រកាសលេខ ៤៣០ សហវ.មប្រក ស្ដីពីការបង្កើត និងតែងតាំងភ្នាក់ងារបើកផ្ដល់សំរាប់បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ	១៥៣៣

១៩-៩-១៩៩៦	ប្រកាស លេខ ៤៣១ សហវ.មប្រក ស្តីពីការបង្កើតរដ្ឋទេយ្យ ចំណូលនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	១៥៣៥
១៩-៩-១៩៩៦	ប្រកាសលេខ ៤៣២ សហវ.មប្រក ស្តីពីការតែងតាំងរដ្ឋទេយ្យករ ចំណូលនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	១៥៣៩
១៩-៩-១៩៩៦	ប្រកាស លេខ ៤៣៣ សហវ.មប្រក ស្តីពីការបង្កើតរដ្ឋទេយ្យ បុរេប្រទាន នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	១៥៤១
១៩-៩-១៩៩៦	ប្រកាស លេខ ៤៣៤ សហវ.មប្រក ស្តីពីការតែងតាំងរដ្ឋទេយ្យករ បុរេប្រទាន នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	១៥៤៣

២ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - ក្រសួងអប់រំ យុវជន និង កីឡា

២៣-៩-១៩៩៦	ប្រកាសលេខ ៤៧៦ សហវ.មប្រក ស្តីពីការបង្កើតរដ្ឋទេយ្យ បុរេប្រទាន នៅក្រសួងអប់រំ យុវជន និងកីឡា	១៥៤៥
២៣-៩-១៩៩៦	ប្រកាសលេខ ៤៧៧ សហវ.មប្រក ស្តីពីការបង្កើតរដ្ឋទេយ្យ ចំណូល នៅក្រសួងអប់រំ យុវជន និងកីឡា	១៥៤៧
២៣-៩-១៩៩៦	ប្រកាសលេខ ៤៧៨ សហវ.មប្រក ស្តីពីការតែងតាំងរដ្ឋទេយ្យករ បុរេប្រទាន នៅក្រសួងអប់រំ យុវជន និងកីឡា	១៥៤៨
២៣-៩-១៩៩៦	ប្រកាសលេខ ៤៧៩ សហវ.មប្រក ស្តីពីការបង្កើត និងតែងតាំង ភ្នាក់ងារបើកផ្តល់សំរាប់បើកបៀវត្សជូនមន្ត្រីរាជការ នៅក្រសួង អប់រំ យុវជន និងកីឡា	១៥៥០
២៣-៩-១៩៩៦	ប្រកាសលេខ ៤៨០ សហវ.មប្រក ស្តីពីការបង្កើតរដ្ឋទេយ្យ បុរេប្រទាន នៅក្រសួងអប់រំ យុវជន និងកីឡា	១៥៥២
២៣-៩-១៩៩៦	ប្រកាសលេខ ៤៨១ សហវ.មប្រក ស្តីពីការតែងតាំងរដ្ឋទេយ្យករ ចំណូល នៅក្រសួងអប់រំ យុវជន និងកីឡា	១៥៥៤
២៣-៩-១៩៩៦	ប្រកាសលេខ ៤៨២ សហវ.មប្រក ស្តីពីការបង្កើតរដ្ឋទេយ្យ បុរេប្រទាន នៅក្រសួងអប់រំ យុវជន និងកីឡា	១៥៥៦

៣ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - ក្រសួងទេសចរណ៍

២៣-៩-១៩៩៦	ប្រកាសលេខ ៤៧០ សហវ.មប្រក ស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទាន ក្រសួងទេសចរណ៍	១៥៥៨
២៣-៩-១៩៩៦	ប្រកាសលេខ ៤៨៣ សហវ.មប្រក ស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទាន នៅក្រសួងទេសចរណ៍	១៥៦០
២៣-៩-១៩៩៦	ប្រកាសលេខ ៤៨៤ សហវ.មប្រក ស្តីពីការបង្កើតរជ្ជទេយ្យចំណូល នៅក្រសួងទេសចរណ៍	១៥៦២
២៣-៩-១៩៩៦	ប្រកាសលេខ៤៨៥ សហវ.មប្រក ស្តីពីការបង្កើត និងតែងតាំងភ្នាក់ងារបើកផ្តល់សំរាប់បើកបៀវត្សជូនមន្ត្រីរាជការ	១៥៦៤
២៣-៩-១៩៩៦	ប្រកាសលេខ ៤៨៦ សហវ.មប្រក ស្តីពីការតែងតាំងរជ្ជទេយ្យករចំណូល នៅក្រសួងទេសចរណ៍	១៥៦៧

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

១៦-៩-១៩៩៦	ប្រកាសលេខ ៥៤១ ឧក.ប្រក អនុញ្ញាតអោយលោក ម៉ៅ ស៊ីណាត ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនស្រូវ កំលាំង ៤០ សេះ	១៥៦៩
១៨-៩-១៩៩៦	ប្រកាសលេខ ៥៦៣ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនថាកក្រាល ខេមបូឌា អ៊ិនដាស្ទ្រីស៍ លីមីធីដ (THAKRAL CAMBODIA INDUSRIES LIMITED) តំណាងដោយលោក GURMUKH SINGH THAKRAL សញ្ជាតិសឹង្ហបុរី បង្កើតរោងចក្រតម្លើងទូរទស្សន៍ និងគ្រឿងបរិក្ខារអេឡិចត្រូនិចនាំចេញ	១៥៦៩

១៩–៩–១៩៩៦ ប្រកាសលេខ ៥៦៩ ផក.ប្រក ស្តីពីការផ្ទេរកម្មសិទ្ធិអាគារ និងដី សម្ព័ន្ធបារីកម្ពុជា ១៥៧០

៥ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ប្រកាស

២៣–៩–១៩៩៦ ប្រកាសលេខ ១១០ បល.កបទ.សអ កែប្រែសមាសភាពគណៈកម្មការបច្ចេកទេស កែទំរង់រដ្ឋបាលប្រចាំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១៥៧២

៦ - ទីស្តីការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

១៩–៩–១៩៩៦ ប្រកាសលេខ ១៥៨ បទ.ប្រក ស្តីពីការតែងតាំងបដិគ្គាហកៈរង មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តតាកែវ ១៥៧៣

៧ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

២៣–៩–១៩៩៦ ប្រកាសលេខ ២៩៧ ពណ.បល.ប្រក ស្តីពីការបង្កើតការិយាល័យប្រព័ន្ធអនុគ្រោះទូទៅ (G.S.P) ចំណុះនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស នៃក្រសួងពាណិជ្ជកម្ម ១៥៧៥

៨ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

២០–៩–១៩៩៦ ប្រកាសលេខ ៨២១ អយក.ប្រក ស្តីពីការបើក « អនុវិទ្យាល័យ សម្តេចក្រុមព្រះ នរោត្តម រណប្ញទ្ធិ » ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ១៥៧៧

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ក្រឹត្យ

ក្រឹត្យ ៩ស/អកត/០៧៩៦/៣៦

ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៧ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការតែងតាំងឯកឧត្តម សារ៉ាក់ ខាន់ ជាអគ្គនាយកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរចាំបាច់នៃការងារ

បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **សារ៉ាក់ ខាន់** អគ្គនាយកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ថែមពីលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០៩៩៦/៦៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

ឯកឧត្តម ស ខេង

ជា

ឧកញ៉ា

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៩៩៦/៧០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

ឯកឧត្តម ឯម សំអាន

ជា

ឧកញ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៩៩៦/៧១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

ឯកឧត្តម គង់ គីម

ជា

ឧកញ៉ា

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៩៩៦/៧២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់សេចក្តីប្រកាស ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦ និង សេចក្តីថ្លែងការណ៍ របស់លោក អៀង សារី ប្រធានចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៩៦
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានលើកលែងទោសអោយលោក **អៀង សារី** អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ច ការបរទេស ក្នុងរដ្ឋាភិបាលនៃប្រទេសកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានផ្តន្ទាទោសប្រហារ ជីវិតបង់ និង រឹបអូសទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជន បដិវត្តក្រុងភ្នំពេញ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ និង ចំពោះទោសដែលបានកំណត់ ដោយច្បាប់ ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យ អោយនៅក្រៅច្បាប់ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស/៩៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

មាត្រា ២ : ព្រះរាជក្រឹត្យនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

មាត្រា ៣ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេចជាស្ថាពរ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៧១ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិជូនចំពោះស្ថានទូត នៃ សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់អំណោយជាទឹកប្រាក់ចំនួន ១០.១០០ ដុល្លារសហរដ្ឋអាមេរិក សំរាប់សាងសង់អាគារសិក្សាមួយខ្នង នៅក្នុងអនុវិទ្យាល័យសេរីភាព ស្រុកតាខ្មៅ ខេត្តកណ្តាល ។

មាត្រា ២ . សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត កណ្តាល ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៧២ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិជូនលោកយាយ ឌី ម៉ុក ដែលមានសទ្ធាជ្រះថ្លា បរិច្ចាគបច្ច័យចំនួន ៥៨.៥៣០$US សំរាប់កសាងព្រះវិហារនៅក្នុងវត្តក្តិល ឃុំត្រពាំងគង ស្រុក សំរោងទង ខេត្តកំពង់ស្ពឺ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ ក្រសួងធម្មការនិងសាសនា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវ អនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៧៣ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិជូនសប្បុរសជន ១៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកកសាងសមិទ្ធផលផ្សេង ៗ ជូនជាតិ ដូចមានរាយនាមខាង ក្រោមនេះ ÷

១_ឯកឧត្តម **ម៉ាត់ លី** បរិច្ចាគប្រាក់ ១១.០០០$US
២_ឯកឧត្តម **អ៊ុំ សារី** បរិច្ចាគប្រាក់ ១០.០០០$US
៣_ឯកឧត្តម **ឈុន ស៊ឹរុន** បរិច្ចាគប្រាក់ ១២.០០០$US
៤_ឯកឧត្តម **ឆោត ខន** បរិច្ចាគប្រាក់ ១២.០០០$US
៥_លោក **ម៉ក់ សំអឿន** បរិច្ចាគប្រាក់ ១២.០០០$US
៦_លោក **គីម ប៊ុនថាន** បរិច្ចាគប្រាក់ ១៤.០០០$US
៧_លោក **នៅ ម៉េងស្រ៊ាង** បរិច្ចាគប្រាក់ ១២.០០០$US
៨_លោក **មាស សឿន** បរិច្ចាគប្រាក់ ២០.០០០$US
៩_លោក **នួន ផា** បរិច្ចាគប្រាក់ ១០.៥០០$US
១០_លោក **រួយ ឈុនលី** បរិច្ចាគប្រាក់ ១០.០០០$US
១១_លោក **ញ៉ូ ជុំវិណា** បរិច្ចាគប្រាក់ ១០.៥០០$US
១២_លោក **ស៊ិន សារ៉េត** បរិច្ចាគប្រាក់ ១០.០០០$US
១៣_លោក **ខឹម ច័ន្ទគីរី** បរិច្ចាគប្រាក់ ១០.៥០០$US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត កណ្តាល ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៧៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនចំពោះសប្បុរសជន ០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកកសាងសមិទ្ធផលផ្សេងៗ

ជូនជាតិ ដូចមានរាយនាមខាងក្រោមនេះ ÷

១_ឯកឧត្តម **ស ខេង** បរិច្ចាគប្រាក់ ១០៩.០០០$US

២_ឯកឧត្តម **ឯម សំអាន** បរិច្ចាគប្រាក់ ១០៤.០០០$US

៣_ឯកឧត្តម **គន់ គីម** បរិច្ចាគប្រាក់ ១១៨.៥៥៥$US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេត្តកណ្តាល ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបាន លល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណប្ញទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៧៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

– តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិជូនចំពោះសប្បុរសជន ដែលបានបរិច្ចាគថវិកា ចូលរួមកសាងសមិទ្ធផលនានានៅក្នុងវិទ្យាល័យទេពប្រណម្យ ស្រុក ពញាឮ ខេត្តកណ្តាល ដូចមាន រាយនាមតាមលំដាប់ថ្នាក់ខាងក្រោម ៖

ក_មេដាយមាសស្ថាបនាជាតិ

១_លោក KJEL HANSAN ប្រធានអង្គការដែនដីមនុស្ស នៃប្រទេសដាណឺម៉ាក

២_លោកស្រី PEN SAK លេខាធិការអង្គការដែនដីមនុស្សនៃប្រទេសដាណឺម៉ាក

លោក និង លោកស្រី ខាងលើ បានបរិច្ចាគថវិកាចំនួន ១៥៨.១៧៧$US

៣_លោក FRANS VANDIJK ប្រធានអង្គការដែនដីមនុស្សនៃ ប្រទេសហូឡង់ បរិច្ចាគថវិកា ២៩.៦២៨$US

៤_លោកប្រធានអង្គការសហប្រតិបត្តិការអន្តរជាតិ បរិច្ចាគថវិកា ២៩.២០០$US

៥_សម្តេចព្រះសង្ឃរាជ **ទេព វង្ស** បរិច្ចាគថវិកា ១២.៥០០$US

៦_លោក VALTER ACHOMONEIT បរិច្ចាគថវិកា ១៥.០០០$US

៧_លោក **ពេញ ស្ងួន** បរិច្ចាគថវិកា ១៥.០០០$US

៨_លោក **គង់ វស្សៀន** បរិច្ចាគថវិកា ២០.៥០០$US

៩_លោក **ឆុន ធឿន** បរិច្ចាគថវិកា ១៣.៦០០$US

១០_លោក **ទ្រោន ទ៊ិវ** បរិច្ចាគថវិកា ១២.៧០០$US

១១_លោក **ឡុង សុខ** បរិច្ចាគថវិកា ១៨.៧០០$US

១២_កញ្ញា **ភូក ណារ៉ា** បរិច្ចាគថវិកា ៧៥.២០០$US

ខ_មេដាយប្រាក់ស្ថាបនាជាតិ

១_ឯកឧត្តម **ម៉ុម ជីមហ៊ុយ** បរិច្ចាគថវិកា ៩.៥០០$US

២_លោក **អៀម ស៊្រុន** បរិច្ចាគថវិកា ៨.៥០០$US

៣_កញ្ញា **ប្រាក់ មួយ** បរិច្ចាគថវិកា ៦.២០០$US

គ_មេដាយសំរិទ្ធស្ថាបនាជាតិ .

១_គណបក្សប្រជាជន ខេត្តកណ្តាល បរិច្ចាគថវិកា ១.០៨០$US

លោក ឧកញ៉ា **ថៃ ហុកឈួរ** បរិច្ចាគថវិកា ៥.២០០.០០០រៀល

៣_លោកតា **ហ៊ុន នាង** បរិច្ចាគថវិកា ១.២៥០$US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេត្តកណ្តាល ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៧៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ប្រគេន និង ជូនសប្បុរសជន ដែលបានបរិច្ចាគ ថវិកាជួយសាងសង់អាគារសម្ភព និងអាគារស្នាក់ នៅក្នុមណ្ឌលសុខភាព ជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាមនិងនាមខាងក្រោមនេះ ÷

ក_មេដាយមាសស្ថាបនាជាតិ

- អ្នកស្រី **សុក អ៊ុំម** បរិច្ចាគថវិកា ១០.០០០$US

ខ_មេដាយប្រាក់ស្ថាបនាជាតិ

- ព្រះតេជគុណ **សាន មុនី** ចៅអធិការវត្ត គលព្រឹក្ស បរិច្ចាគថវិកា ៥.០០០$US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណប្ញទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៧៧ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិជូនលោក **ឆាយ អេង** តំណាង ក្រុមហ៊ុន PELICO WOOD ដែលបានជួយជួសជុលរបង និងក្រាលឥដ្ឋក្រ ឡាជុំវិញវាលព្រះមេរុ ដោយចំណាយ ថវិកាក្រុមហ៊ុនអស់ចំនួន ១៣៩.៩៩០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រតិភូរាជ រដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៧៨ អនក្រ .តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិជូនអង្គការអន្តរជាតិ ដែលបានជួយសាងសង់អាគារសិក្សានៅតាមសាលាបឋមសិក្សា នានាក្នុងរាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោមនេះ ÷

១- អង្គការ REDD BARNA ចំណាយអស់ទឹកប្រាក់សរុប ២៣០.០០០ $US

២- អង្គការក្រុមកំលាំងយុវជនជប៉ុនJHP ចំណាយអស់ទឹកប្រាក់សរុប ២៥.០០០ $US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ

អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១៧៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សំរេច

មាត្រា ១ : ត្រូវបានប្រគលមេដាយ«មាស »ស្ថាបនាជាតិ ជូនមន្ត្រីបារាំង ០៥ រូប ដែលមានស្នាដៃល្អ ក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍ មន្ទីរពេទ្យកាល់ម៉ែត អោយមានលក្ខណៈទំនើបលើគ្រប់ផ្នែក ដូចមាន រាយនាមខាងក្រោមនេះ ÷

១–ឯកឧត្តម Gildas le LIDEC ឯកអគ្គរដ្ឋទូត

២–លោក Jean-Pierre ALLUARD អគ្គប្រតិភូមន្ទីរពេទ្យកាល់ម៉ែត

៣–លោកសាស្ត្រាចារ្យមហាបរិញ្ញា Yves BREDA អ្នកទំនាក់ទំនងផ្នែកវះកាត់

៤–លោកវេជ្ជបណ្ឌិត Francois LAHAYE អ្នកទំនាក់ទំនងផ្នែកសង្គ្រោះបន្ទាន់និងប្រពោនកម្ម

៥–លោក Jean Claude PRANDY អ្នកទំនាក់ទំនងកម្មវិធីអង្គការគ្រូពេទ្យពិភពលោក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ១៨០ អនក្រ តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើចាំបាច់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សំរេច

មាត្រា ១ : តែងតាំងលោក **គង់ថៃ ប៊ុនថន** លោក **គុក សុខគីម** និងលោក **នួន ទ័ាត** ជាទីប្រឹក្សា ឯកឧត្តមរដ្ឋមន្ត្រី ។

មាត្រា ២ : រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួង រដ្ឋលេខាធិកានៃរដ្ឋលេខាធិការដ្ឋាន គ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ លោក **គង់ថៃ ប៊ុនថន** លោក **គុក សុខគីម** និងលោក **នួន ទ័ាត** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ១៨១ អនក្រ.តត

ស្តីពីការផ្ទេរភារកិច្ចនាយទាហាន

នៃកងយោធពលខេមរភូមិន្ទ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហា ក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកា
អោយប្រើ ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
– ពិនិត្យតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ចលោក ឧត្តមសេនីយ៍ត្រី **គឹម ហាន** ពីមេបញ្ជាការរង យោធភូមិភាគពិសេសអោយមកទទួលជាទីប្រឹក្សា ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ត្រូវបានផ្ទេរក្របខ័ណ្ឌមួយកន្លែងពីកងយោធពលខេមរភូមិន្ទអោយក្រសួងមហាផ្ទៃជាអ្នក គ្រប់គ្រងបន្ត ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋម ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងលោកឧត្តមសេនីយ៍ត្រី **គឹម ហា** ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃ ឡាយព្រះហស្តលេខានិងចុះហត្ថលេ តទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩

សេចក្តីសំរេច លេខ : ៣៩ សសរ

ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សំរាប់រៀបចំ ពិធីបុណ្យខួបអនុស្សាវរីយ៍ ៥ឆ្នាំលើកទី ១ នៃកិច្ចព្រមព្រៀងសន្តិភាពកម្ពុជា នាទីក្រុងប៉ារីស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងស្មារតីសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ២១ សីហា ឆ្នាំ ១៩៩៦
- យោងតាមសំណូមពរការងារចាំបាច់ចំពោះមុខ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងសំរាប់រៀបចំបុណ្យខួបអនុស្សាវរីយ៍ ៥ ឆ្នាំ លើកទី ១ នៃទិវាកិច្ចព្រមព្រៀងសន្តិភាពកម្ពុជា នាទីក្រុងប៉ារីស ដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង		ប្រធាន
២-ឯកឧត្តម **អ៊ុច គឹមអន**	រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៣-ឯកឧត្តម **មិន ឃិន**	អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការបុណ្យជាតិ និងអន្តរជាតិ	សមាជិក
៤-ឯកឧត្តម **ឆាយ ថន**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
៥-ឯកឧត្តម **ខួច ម៉េងហ៊ាន**	អភិបាលរងសាលាក្រុងភ្នំពេញ	សមាជិក

ប្រការ ២ : គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ ÷

- ព្រាងសារាចរណែនាំ អំពីការរៀបចំពិធីបុណ្យនេះ អោយបានប្រព្រឹត្តទៅ យ៉ាងអធិកអធម ក្នុងទូទាំងប្រទេស ។
- អញ្ជើញអ្នកមានគំនិតផ្តើមសន្តិភាព និងតំណាងប្រទេសហត្ថលេខីចូលរួម
- រៀបចំពិធីមីទ្ទិញ ព្រមទាំងគ្រឿងឥស្សរិយយស សំរាប់បំពាក់ជូន ឥស្សរជនបរទេស សំខាន់ៗ ដែលបានរួមចំណែកដល់ ដំណើរការ សន្តិភាពនៅកម្ពុជា ។
- លើកគំរោងថវិកាសំរាប់ការចំណាយក្នុងពិធីបុណ្យនេះ និងអនុវត្តចំណាយ តាមបែបបទដូច កន្លងមក
- ស្នើសុំមតិសំរេចពីរាជរដ្ឋាភិបាលក្នុងករណីដែលគណៈកម្មការនេះ មិន មានលទ្ធភាពដោះស្រាយបាន ។

ប្រការ ៣ : គណៈកម្មកាអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួនតាម ការចាំបាច់ដើម្បីជំនួយការ ។

ប្រការ ៤ : គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រាជាផ្លូវការរបស់ទីស្តីការ គណៈរដ្ឋមន្ត្រី ។

ប្រការ ៥ : សមាជិកគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រការ ៦ : គណៈកម្មការអន្តរក្រសួងនេះ និងត្រូវរំសាយក្រោយពីចប់ពិធីបុណ្យជាស្វ័យ ប្រវត្តិ ។

ប្រការ ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រតិភូរាជ រដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ប្រធានគណៈកម្មាធិការបុណ្យ ជាតិ និងអន្តរជាតិ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីសំរេច នេះចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

៣ - សារាចរណែនាំ

រាជធានីភ្នំពេញ ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

សារាចរណែនាំ លេខ : ០៥ សរ.ណន

ស្តីពីការរៀបចំខួបអនុស្សាវរីយ៍លើកទី ៥ នៃទិវា
ចុះហត្ថលេខា លើកិច្ចព្រមព្រៀង ដើម្បីសន្តិភាពកម្ពុជា នាទីក្រុងប៉ារីស
២៣ - ១០ - ៩១ — ២៣ - ១០ - ១៩៩៦

ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ គឺជាទិវាប្រវត្តិសាស្ត្រ នៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងដើម្បីសន្តិភាពកម្ពុជានាទីក្រុងប៉ារីស ដោយមានបណ្តាប្រទេស ជាហត្ថលេខីចំនួន១៩ ប្រទេស នៃសហគមន៍អន្តរជាតិចូលរួមនៅចំពោះវត្តមាន នៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ គឺថ្ងៃទី ២៣ ខែ តុលានេះហើយ ដែលប្រជាពលរដ្ឋខ្មែរគ្រប់រូបបានចារិកជាប់នៅក្នុងជីវិតរបស់ខ្លួនថា ជាដំណើរចាប់ផ្តើមនៃការបញ្ចប់សង្គ្រាមរ៉ាំរ៉ៃ ការបង្រួបបង្រួមផ្សះផ្សាជាតិ ការកសាងសន្តិភាព ការស្តារ និង អភិវឌ្ឍន៍ប្រទេសកម្ពុជាជាថ្មីឡើងវិញ ។

ដើម្បីសំដែងនូវអំណរសាទរ សប្បាយរីករាយ ទទួលស្វាគមន៍ខួបអនុស្សាវរីយ៍ ៥ ឆ្នាំ នៃទិវាជាប្រវត្តិសាស្ត្រនេះ និងដើម្បីសំដែងការដឹងគុណចំពោះអង្គការសហប្រជាជាតិជាពិសេស បណ្តាប្រទេសហត្ថលេខីទាំង ១៩ ប្រទេស ដែលបានជួយឧបត្ថម្ភដល់ដំណើរការសន្តិភាពនៅកម្ពុជា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចេញសារាចរណែនាំដល់បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ខេត្ត ក្រុង ដូចតទៅនេះ÷

ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩៦ ខាងមុខនេះ នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជានឹងត្រូវរៀបចំ ពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៥ នៃទិវាចុះហត្ថលេខាលើកិច្ចព្រមព្រៀងដើម្បីសន្តិភាពកម្ពុជា នាទីក្រុងប៉ារីស (២៣–១០–៩១–២៣–១០–៩៦) ។

• ទីស្តីការគណៈរដ្ឋមន្ត្រី : ត្រៀមលក្ខណៈអោយបានល្អ ដោះស្រាយនូវរាល់សំណូមពរទាំងស្មារតី និងទាំងសម្ភារៈ ថវិកា ជូនក្រសួងពាក់ព័ន្ធ ដែលត្រូវការចាំបាច់សម្រាប់បំរើការរៀបចំបុណ្យខួបលើកទី ៥ នៃទិវាជាប្រវត្តិសាស្ត្រនេះអោយបានឧឡារិក អធិកអធមស្របតាមគោលបំណង និងសំណូមពរ ។

• ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ : ត្រៀមលក្ខណៈរៀបចំធ្វើសិក្ខាសាលា អញ្ជើញភ្ញៀវបរទេស ជាប្រទេសហត្ថលេខីទាំង ១៩ ប្រទេស ទាំងនៅក្នុងរដ្ឋាភិបាល និង ក្រៅរដ្ឋាភិបាល ទំនាក់ទំនងទទួល - ជូនដំណើរ - សណ្ឋាគារស្នាក់នៅ និងពិធីការអោយបានល្អ ព្រមទាំងតាក់តែងសុន្ទរកថា និងឯកសារផ្សេងៗ ដែលពាក់ព័ន្ធ នឹងទិវា ២៣ ខែតុលានេះ និងលើកសំណើជូនគ្រឿងឥស្សរិយយស ។

• គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ : ត្រៀមលក្ខណៈរៀបចំមីទ្ទីញមួយនៅទីលាន មុខព្រះបរមរាជវាំង ដែលមានថ្នាក់ដឹកនាំមន្ត្រីរាជការ - អ្នកមុខអ្នកការ សិស្ស - និស្សិត និងប្រជាពលរដ្ឋ - ភ្ញៀវអន្តរជាតិចូលរួម អោយបានច្រើនកុះករ ដោយមានទង់ជាតិប្រទេសទាំង ១៩ ទង់ក្លែប អាហ្វីស ប៉ង់កាត បដា ពាក្យស្លោក និងតុបតែងលំអធានាអោយបានល្អបភាពចាត់តាំង និងខ្លឹមសារ ។

• សាលាក្រុងភ្នំពេញ : ចាត់តាំងកំលាំងមហាជនចូលរួមមីទ្ទិញនៅ មុខព្រះបរមរាជវាំង ។ រក្សាសន្តិសុខរបៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរ តាំងភ្លើងពណ៌ និងសិល្បៈតន្ត្រីបុរាណសម័យ ប្រគុំសំដែងជូនមហាជនទស្សនាតាមទីធ្លាសាធារណៈ ។

• គ្រប់ខេត្ត-ក្រុង : ត្រូវចាត់តាំងរៀបចំពិធីមីទ្ទីញមួយ នៅក្នុងក្របខ័ណ្ឌខេត្ត ក្រុងរបស់ខ្លួនអោយបានឧឡារិកអធិកអធម ដោយមានថ្នាក់ដឹកនាំ ខេត្ត ក្រុង មន្ត្រីរាជការ ខ័ណ្ឌ ស្រុក និងប្រជាពលរដ្ឋចូលរួម និងមានចាត់តាំងសិល្បៈតន្ត្រី សំដែងជូនមហាជនទស្សនានៅ ថ្ងៃទី ២៣ ខែ តុលា ១៩៩៦ តាមទីធ្លាសាធារណៈ ។

• ក្រសួងពត៌មាន : ត្រៀមលក្ខណៈចងក្រងខ្លឹមសារ អត្ថបទធ្វើបទសម្ភាសន៍ផ្សព្វផ្សាយឡើងវិញ ស្តីពីទិវាចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពកម្ពុជា នាទីក្រុងប៉ារីស តាមបណ្តាញវិទ្យុ ទូរទស្សន៍ និងសារពត៌មាន ។

• ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រៀមដោះស្រាយសិល្បៈមួយក្រុមសំរាប់សំដែងនៅក្នុងឱកាស ជប់លៀង ។

• ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សហការត្រៀមលក្ខណៈ និងមានផែនការបង្កើនសមត្ថភាព ការពារ រក្សាសន្តិសុខ ធានាសុវត្ថិភាព ក្នុងពេលប្រារព្ធពិធីបុណ្យ ។

• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ : ត្រៀមលក្ខណៈដោះស្រាយថវិកាសម្រាប់បំរើការរៀបចំខួបលើកទី៥ នៃទិវា ២៣ តុលានេះ អោយបានសមស្រប និង ទាន់ពេលវេលា ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តម ប្រធាន ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត ក្រុងចាត់តាំងអនុវត្តដោយគំនិតច្នៃប្រឌិត អោយបានលទ្ធផលល្អប្រសើរ និងរាយការណ៍ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី ក្រោយបានអនុវត្តស្មារតីសារាចរណែនាំនេះ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III - ការងារបណ្តាក្រសួង

ប្រកាសអន្តរក្រសួង

១ - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ - ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ : ៤៣០ សហវ.មប្រក

ស្តីពីការបង្កើត និង កែងតាំងភ្នាក់ងារបើកផ្តល់សំរាប់បើកបៀវត្សជូនមន្ត្រីរាជការ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

– បានឃើញរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

- យោងព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤–៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសដោយព្រះ រាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ វិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជា ទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិត ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន

សំរេច

ប្រការ ១ : ប្រាក់បៀវត្សមន្ត្រីរាជការនៃក្រសួងការបរទេស និង សហប្រតិបត្តិអន្តរជាតិ នឹងត្រូវបើកផ្តល់ តាមរយៈរដ្ឋទេយ្យករ ដែលមានឈ្មោះថា ÷ « ភ្នាក់ងារបើកផ្តល់ » ។

ប្រការ ២ : លោក **សម ឃួរ** «ក» ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់នៅក្រសួងការបរទេស និងលោកស្រី **គង់ ម៉ាណនាទី** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់ជំនួស ។

ប្រការ ៣ : លោក «ក »ត្រូវបានអនុញ្ញាតអោយបើកគណនីប្រាក់បញ្ញើនៅរតនាគារជាតិ (ឬរតនាគារខេត្ត ក្រុង) ដើម្បីទទួលមូលនិធិសំរាប់យកទៅបើកបៀវត្សជូនមន្ត្រីរាជការ ។

ប្រការ ៤ : បែបបទនៃការអនុវត្តន៍បើកផ្តល់បៀវត្ស នឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

ប្រការ ៥ : ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និង មូលនិធិបានទទួល ដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

ប្រការ ៦ : សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ៧ : ខុទ្ទកាល័យ មន្ទីរ នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញវត្ថុ រតនាគារជាតិ ព្រមទាំងនាយកដ្ឋាន ពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទាំង អស់ និង ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិព្រមទាំង លោក **សម ហួរ** ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងការបរទេស	រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
អ៊ឹង ហួត	**គាត ឈន់**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ : ៤៣១ សហវ.ប្រក

ស្តីពីការបង្កើតរដ្ឋបាលប្រាក់បៀវត្សនៅក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ប១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទ បញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ....ចុះថ្ងៃទី ខែ ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋទេយ្យចំណូល
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានបង្កើតរដ្ឋទេយ្យចំណូលនៅក្រសួងការបរទេស ដើម្បីធ្វើការប្រមូលនូវចំណូលដូចតទៅនេះ :

បញ្ជីរាយប្រភេទចំណូល ផលដែលរដ្ឋទេយ្យករត្រូវបានអនុញ្ញាតអោយប្រមូល

ប្រការ ២ : ចំនួនទឹកប្រាក់អតិបរមា ដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹម ចំនួនពីរលានរៀល (២.០០០.០០០៛) ។

ប្រការ ៣ : សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយ នឹង ប្រកាសនេះត្រូវចាត់ទុកជា និរាករណ៍ ។

ប្រការ ៤ : មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ...មមាងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោម ឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវ... និងក្រសួងការបរទេស និងសហប្រតិ អន្តរជាតិ ត្រូវទទួលបន្ទុក...នុវត្តតាមប្រកាសនេះចាប់ពី ថ្ងៃចុះហត្ថ ភតទៅ ។

រដ្ឋមន្ត្រីក្រសួងការបរទេស
ហត្ថលេខា និង ត្រា
អ៊ុង ហួត

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

* * *

ក្រសួងការបរទេស និង
សហប្រតិបត្តិការអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បញ្ជីរាយប្រភេទចំណូល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ខ្លឹមសារចំណូល	ផ្សេង ៗ
២០				ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	
	០៦			ការជួលអចលនៈវត្ថុ	
				ស្ថានទូតហុងគ្រី	
				ស្ថានទូតឥណ្ឌា	
				ស្ថានទូតជប៉ុន	

				កាកបាទក្រហមអន្តរជាតិ	
				ក្រុមហ៊ុនទ្រីស្តា	
				ក្រុមហ៊ុនសែល	
				ក្រុមហ៊ុនសាន់តិច	
				លោក ចាន់ គឹមយិន	
				លោក ឯម ប៊ុនថា	
				លោក ឌឹម គឹមស៊ិន	
២១				ចំណូលផ្សេងៗពុំមែនសារពើពន្ធ	
	០៣			ចំណូលនៃសេវាសាធារណៈ	
		០៣		អាករនៃស្ពានទូត	
				បាងកក	
				វៀងច័ន្ទ	
				ហូជីមិញ	
				ហ្សាកាតា	
				កំប៉ែរ៉ា	
				ញូវដេលី	
				ញូវយ៉ក	
				បោន	
				ប៊ុយដាប៉េស្ត	
				ម៉ូស្គូ	
				តូក្យូ	
				ប៉ារីស	

				ប៉េកាំង	
				ប្រាគ	

បានឃើញ និង ឯកភាព បានពិនិត្យត្រឹមត្រូវ ភ្នំពេញ ថ្ងៃទី ១០ ខែ ៩ ឆ្នាំ ១៩៩៦

រដ្ឋមន្ត្រី ជ. ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ការិយាល័យហិរញ្ញកិច្ច

ហត្ថលេខា និង ត្រា គណនេយ្យ អនុ

អ៊ុង ហួត ហត្ថលេខា ហត្ថលេខា

សម សាមុត **ប៊ុន សារិទ្ធ**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួងលេខ ៤៣២ ស.ហ.វ.មប្រក

ស្តីពីការតែងតាំងវេជ្ជនេយ្យក្រចំណូល

នៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
– យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
– យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ តុលា ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញា ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០២ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត រដ្ឋនេយ្យករចំណូល
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងលោក **ម៉ុន សារិទ្ធ** ឋានៈអនុប្រធានការិយាល័យនាយកដ្ឋានហិរញ្ញវត្ថុ គណនេយ្យ អោយទទួលការងារជារដ្ឋនេយ្យករចំណូលនៅអមក្រសួងការបរទេស និង សហប្រតិបត្តិ ការអន្តរជាតិ និង លោក **ហាស់ ឈឿន** មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ–គណនេយ្យ ជារដ្ឋនេយ្យករចំណូលជំនួស ។

ប្រការ ២ : ការតែងតាំងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ខែ ឆ្នាំ ១៩៩៦ នេះតទៅ។

ប្រការ ៣ : មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការបរទេស និងប្រតិបត្តិ

ការអន្តរជាតិ ព្រមទាំងលោក **ម៉ីន សារិទ្ធ** និងលោក **ហាស់ ឈឿន** ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

	ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការបរទេស	ទទួលបន្ទុកទីតិសម្បទានិង អភិវឌ្ឍន៍
និង សហប្រតិបត្តិការអន្តរជាតិ	រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
អ៊ុង ហួត	**គាត ឈន់**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ខែ ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ ៤៣៣ ស.ហ. វ.មប្រក

ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានរៀបចំ

នៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ តុលា ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញា ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ចុះថ្ងៃទី ខែ ឆ្នាំ ១៩៩៦ ស្តីពីការប្រព្រឹត្តិទៅនៃរជ្ជទេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាននៅក្រសួងការបរទេស ដើម្បីទូទាត់ចំណាយទាំងឡាយដែល មានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អន.ក្របក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីអំពីបទបញ្ញាទូទៅនៃ គណនេយ្យសាធារណៈ ។

ចំនួនទឹកប្រាក់ជាអតិបរមា នៃចំណាយដែលអនុញ្ញាតអោយរជ្ជទេយ្យបុរេប្រទានធ្វើការទូទាត់ត្រូវ កំណត់ដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ២ : ចំនួនទឹកប្រាក់ នៃរជ្ជទេយ្យបុរេប្រទានត្រូវបានកំណត់ត្រឹមចំនួន ៩០.០០០.០០០ រៀល ។

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងការបរទេស មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
អ៊ុង ហួត	**គាត ឈន់**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ ៤៣៤ ស.ហ.វ.មប្រក

ស្តីពីការតែងតាំងវិជ្ជាជីវៈក្របុរេប្រធាន

នៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ តុលា ១៩៩៥ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះ

រាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០៣១ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការប្រព្រឹត្តិ ទៅនៃរដ្ឋទេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងលោក **ចាប គុជ** ឋានៈប្រធានការិយាល័យនាយកដ្ឋានហិរញ្ញវត្ថុ គណនេយ្យ អោយទទួលការងារបន្ថែមជារដ្ឋទេយ្យករបុរេប្រទាន នៅអមក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ លោកស្រី **ស៊ី ចំន្ទធុន្នី** ឋានៈប្រធានការិយាល័យ និង លោក **អ៊ុម ហេន** មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ គណនេយ្យ ជារដ្ឋទេយ្យករបុរេប្រទានជំនួស ។

ប្រការ ២ : ការតែងតាំងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ខែ ឆ្នាំ ១៩៩៦ នេះតទៅ។

ប្រការ ៣ : មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងលោក **ចាប គុជ** លោកស្រី **ស៊ី ចំន្ទធុន្នី** និង លោក **អ៊ុម ហេន** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងការបរទេស	ទេសរដ្ឋមន្ត្រី
និង សហប្រតិបត្តិការអន្តរជាតិ	រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
អ៊ុង ហួត	**គាត ឈន់**

២ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងអប់រំ យុវជន និង កីឡា

រាជធានីភ្នំពេញ ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ ៤៧៦ ស.ហ.វ.ម.ប្រក
ស្តីពីការបង្កើតវគ្គនេយ្យបុរេប្រធាន
នៅក្រសួងអប់រំ យុវជន និង កីឡា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ តុលា ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញា ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការប្រព្រឹត្តទៅនៃរដ្ឋទេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទានមួយនៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីទូទាត់ចំណាយ ទាំងឡាយដែលមានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អនក្របក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ ។

ចំនួនទឹកប្រាក់ជាអតិបរមា នៃចំណាយដែលអនុញ្ញាតអោយរដ្ឋទេយ្យករបុរេប្រទានធ្វើការទូទាត់ ត្រូវកំណត់ត្រឹមក្រោម ៥០០.០០០ រៀល តាមចំណាត់ថ្នាក់នីមួយ ៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយ ប្រកាសអន្តរក្រសួង ។

ប្រការ ២ : ចំនួនទឹកប្រាក់ នៃរដ្ឋទេយ្យបុរេប្រទាន ត្រូវបានកំណត់ត្រឹមចំនួន ៩.៨៥៣.០០០ រៀល ។

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និង កីឡា មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី	រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
តូល ឡោះ	**ស៊ុន ចាន់ថុល**

រាជធានីភ្នំពេញ , ថ្ងៃទី ខែ ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ ៤៧៧ ស.ហ.វ.មប្រក
ស្តីពីការបង្កើតរដ្ឋលេខាធិការលោក
នៅក្រសួងអប់រំ យុវជន និង កីឡា
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ តុលា ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជា ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញសារាចរណែនាំលេខ ០០២ ស.ហ.វ.ម. ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋទេយ្យចំណូល
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានបង្កើតរដ្ឋទេយ្យចំណូលនៅក្រសួងអប់រំ យុវជន និង កីឡា ដើម្បីធ្វើការប្រមូលនូវ ចំណូលដូចតទៅនេះ :
បញ្ជីរាយប្រភេទចំណូល , ផលដែលរដ្ឋទេយ្យករត្រូវបាន អនុញ្ញាតអោយប្រមូល

ប្រការ ២ : ចំនួនទឹកប្រាក់អតិបរិមា ដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹមចំនួនពីរលានរៀល (២.០០០.០០០៛)

ប្រការ ៣ : សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និង កីឡា ត្រូវទទួលបន្ទុកអនុវត្តតាម ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី	រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
តុល ឡោះ	**ស៊ុន ចាន់ថុល**

* * *

ភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ : ៤៧៨ ស.ហ.វ.ម.ប្រ.ក

ស្តីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន

នៅក្រសួងអប់រំ យុវជន និង កីឡា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១១ន.ស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្របក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញា ទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវមប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញាទូទៅគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការប្រព្រឹត្តិទៅនៃ រជ្ជទេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងលោក **សេង សារិន** ឋានៈ វិស្វករសេដ្ឋកិច្ច តួនាទីប្រធានផ្នែកយុវជន និង កីឡា អោយទទួលការងារ បច្ចុប្បន្នជារដ្ឋលេខាធិការ បុរេប្រទាននៅអមក្រសួងអប់រំយុវជន និងកីឡា ។

ប្រការ ២ : ការតែងតាំងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ខែ ឆ្នាំ ១៩៨៦ នេះតទៅ ។

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងអប់រំយុវជន និងកីឡា ព្រមទាំងលោក **សេង សារិន** មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
ស៊ុន ចាន់ថុល

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា
ហត្ថលេខា និង ត្រា
តុល ឡោះ

* * *

ភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៨៦

ប្រកាសអន្តរក្រសួង លេខ : ៤៧៩ ស.ហ.វ.ម.ប្រ.ក

ស្តីពីការបង្កើត និង តែងតាំងថ្នាក់ឋានៈបើក

ផ្តល់សំរាប់បើកបៀវត្សជូនមន្ត្រីរាជការ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១

ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ន.ស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្របក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវមប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញាទូទៅគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥សហវម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ប្រាក់បៀវត្សមន្ត្រីរាជការ នៃក្រសួងអប់រំយុវជន និង កីឡា នឹងត្រូវបើកផ្តល់តាមរយៈរដ្ឋទេយ្យករ ដែលមានឈ្មោះថា « ភ្នាក់ងារបើកផ្តល់ » ។

ប្រការ ២ : លោក **សេង សារិន** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់ នៅក្រសួងអប់រំយុវជន និងកីឡា និង លោក **យូ បុណ្ណរ្យណា** ត្រូវបានតែងតាំង ជាភ្នាក់ងារបើកផ្តល់ជំនួស ។

ប្រការ ៣ : លោក **សេង សារិន** ត្រូវបានអនុញ្ញាតអោយបើកគណនីប្រាក់បញ្ញើនៅរតនាគារជាតិ (ឬរតនាគារខេត្ត -ក្រុង) ដើម្បីទទួលមូលនិធិសំរាប់យកទៅបើកបៀវត្សជូនមន្ត្រីរាជការ ។

ប្រការ ៤ : បែបបទនៃការអនុវត្តន៍ បើកផ្តល់បៀវត្ស នឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

ប្រការ ៥ : ភ្នាក់ងារបើកផ្តល់ ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាសនិងមូលនិធិដែលបានទទួល ដើម្បី យកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

ប្រការ ៦ : សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ៧ : ខុទ្ទកាល័យ មន្ទីរ នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញកិច្ច រតនាគារជាតិ ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់ និងក្រសួងអប់រំយុវជន និងកីឡា ព្រមទាំងលោក **សេង សារ៉ែន** និងលោក **យូ មុណ្ណរ៉ាណា** ត្រូវទទួលបន្ទុកអនុវត្តតាម ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា
ហត្ថលេខា និង ត្រា
តុល ឡោះ

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ស៊ុន ចាន់ថុល

* * *

ភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ : ៤៧០ ស.ហ.វ.ម.ប្រ.ក

ស្តីពីការបង្កើតរដ្ឋលេខាធិការប្រធាន

នៅក្រសួងអប់រំ យុវជន និង កីឡា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- យោងព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ន.ស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្របក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវមប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញាទូទៅគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវម ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការប្រព្រឹត្តិទៅនៃ រដ្ឋទេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទានមួយនៅក្រសួងអប់រំយុវជន និងកីឡា ដើម្បីទូទាត់ចំណាយទាំងឡាយដែលមានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អនក្របក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ។

ចំនួនទឹកប្រាក់ជាអតិបរិមា នៃចំណាយដែលអនុញ្ញាតអោយរដ្ឋទេយ្យករបុរេប្រទានធ្វើការទូទាត់ត្រូវកំណត់ក្រិតក្រោម ៥០០.០០០ រៀល តាមចំណាត់ថ្នាក់នីមួយ ៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ ភ្ជាប់ជាមួយប្រកាសអន្តរក្រសួង ។

ប្រការ ២ : ចំនួនទឹកប្រាក់នៃរដ្ឋទេយ្យបុរេប្រទានត្រូវបានកំណត់ត្រឹមចំនួន ២៨.៧២៩.៥០០ រៀល ។

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងអប់រំយុវជន និង កីឡា មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា	រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
តុល ឡោះ	**ស៊ុន ចាន់ថុល**

* * *

ភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ : ៤៨១ ស.ហ.វ.ម.ប្រ.ក

ស្តីពីការតែងតាំងរដ្ឋទេយ្យករចំណាយ

នៅក្រសួងអប់រំ យុវជន និង កីឡា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ន.ស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្របក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវមប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញាទូទៅគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវម ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសេចក្តីណែនាំលេខ ០០២ សហវម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើត រដ្ឋទេយ្យចំណូល
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានតែងតាំង **សេខ សារិន** ឋានៈវិសេ្វករសេដ្ឋកិច្ច តួនាទីប្រធានផ្នែកថវិការយុវជន និងកីឡា អោយទទួលការងារបច្ចុប្បន្នជារដ្ឋទេយ្យករចំណូល នៅអមក្រសួងអប់រំ និងកីឡា ។

ប្រការ ២ : ការតែងតាំងនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី ខែ ឆ្នាំ ១៩៩៦ នេះតទៅ ។

ប្រការ ៣ : សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៤ : មន្ទីរ រតនាគារ នាយកដ្ឋានព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ ក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងអប់រំយុវជន និង កីឡា ព្រមទាំង លោក **សេង សារីន** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ហត្ថលេខា និង ត្រា

តុល ឡោះ

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ស៊ុន ចាន់ថុល

* * *

ភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួងលេខ : ៤៨២ ស.ហ.វ.ម.ប្រ.ក

ស្តីពីការបង្កើតរដ្ឋលេខាធិការ

នៅក្រសួងអប់រំ យុវជន និង កីឡា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្របក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៣ សហវមប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រព្រឹត្តិទៅនៃរជ្ជទេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានមួយនៅក្រសួងអប់រំយុវជន និង កីឡា ដើម្បីទូទាត់ចំណាយទាំង ឡាយដែលមានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អនក្របក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ។

ចំនួនទឹកប្រាក់ជាអតិបរិមា នៃចំណាយដែលអនុញ្ញាតអោយរជ្ជទេយ្យករបុរេប្រទានធ្វើការទូទាត់ត្រូវកំណត់ត្រឹមក្រោម៥០០.០០០ រៀល តាមចំណាត់ថ្នាក់នីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ ភ្ជាប់ជាមួយប្រកាសអន្តរក្រសួង ។

ប្រការ ២ : ចំនួនទឹកប្រាក់នៃរជ្ជទេយ្យបុរេប្រទានត្រូវបានកំណត់ត្រឹមចំនួន ១៧.៨០៧.០០០ រៀល ។

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារជាតិ នាយកដ្ឋានព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងអប់រំយុវជន

និងកីឡា មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា
ហត្ថលេខា និង ត្រា
តូល ឡោះ

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ស៊ុន ចាន់ថុល

* * *

៣ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ ៤៧០ ស.ហ.វ.មប្រក

ស្តីពីការបង្កើតរដ្ឋបាលប្រមូលចំណូល នៅក្រសួងទេសចរណ៍

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសំរាប់ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ន.ស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្របក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវមប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញាទូទៅគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ សហវម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការ ប្រព្រឹត្តិទៅ នៃរជ្ជទេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាននៅក្រសួងទេសចរណ៍ ដើម្បីទូទាត់ចំណាយទាំងឡាយដែលមានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យ លេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ ។

ចំនួនទឹកប្រាក់ជាអតិបរមា នៃចំណាយដែលអនុញ្ញាតអោយរជ្ជទេយ្យករបុរេប្រទានធ្វើការទូទាត់ត្រូវកំណត់ក្រិតក្រោម ៥០០.០០០ រៀល តាមចំណាត់ថ្នាក់ចំណាយនីមួយ ៗ ដូចមានចែងនៅក្នុង តារាងឧបសម្ព័ន្ធជាមួយនឹងប្រកាសអន្តរក្រសួងនេះ ហើយត្រូវចំណារដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ២ : ចំនួនទឹកប្រាក់ នៃរជ្ជទេយ្យបុរេប្រទានត្រូវបានកំណត់ត្រឹមចំនួន ៤៩.០០០.០០០ រៀល « ជំពូក ១២ » និង ២៧.០០០.០០០ រៀល សំរាប់ជំពូក ១១ ។

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីៈថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
ទទួលបន្ទុកកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍

រដ្ឋមន្ត្រីក្រសួងទេសចរណ៍
ហត្ថលេខា និង ត្រា
វ៉េង សេរីវុឌ្ឍ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ : ៤៨៣ សហវ.មប្រក
ស្តីពីការតែងតាំងរដ្ឋលេខាធិការបុរសប្រធាន
នៅក្រសួងទេសចរណ៍

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១.ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១១ន.ស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជា ទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ជាទូទៅគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសាចរណែនាំលេខ ០០៣ សហវ.ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការប្រព្រឹត្តិទៅ នៃរដ្ឋនេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានតែងតាំង កញ្ញា **រស់ ផល្លាប** ឋានៈអនុប្រធានការិយាល័យគណនេយ្យ តួនាទី បេឡាការិនី អោយទទួលការងារបច្ចុប្បន្ន ជារដ្ឋនេយ្យករបុរេប្រទាននៅអមក្រសួងទេសចរណ៍។

ប្រការ ២ : ការតែងតាំងនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី ខែ កក្កដា ឆ្នាំ ១៩៩៦ នេះតទៅ ។

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ ព្រមទាំង

កញ្ញា **រស់ ឆវណ្ណាប** ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
ទទួលបន្ទុកកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍

រដ្ឋមន្ត្រីក្រសួងទេសចរណ៍
ហត្ថលេខា និង ត្រា
វ៉េង សេរីវុឌ្ឍ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ : ៤៨៤ សហវ.មប្រក
ស្តីពីការបង្កើតវិជ្ជាធ្យេបំណុល នៅក្រសួងទេសចរណ៍

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១១ន.ស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្របក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវមប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញាទូទៅគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវម ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសាចរណែនាំលេខ ០០២ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរដ្ឋទេយ្យចំណូល
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានបង្កើតរដ្ឋទេយ្យចំណូលនៅក្រសួងទេសចរណ៍ ដើម្បីធ្វើការប្រមូលនូវចំណូលដូចតទៅនេះ : បញ្ជីរាយប្រភេទចំណូល ,ផលដែលរដ្ឋទេយ្យករត្រូវបានអនុញ្ញាតអោយប្រមូល (ភ្ជាប់ជាមួយ តារាងឧបសម្ព័ន្ធ) ។

ប្រការ ២ : ចំនួនទឹកប្រាក់អតិបរមា ដែលអនុញ្ញាតទុកនៅបេឡាជារូបិយវត្ថុមានកំណត់ត្រឹមចំនួន ២.០០០.០០០ (ពីរលានរៀលគត់) ។

ប្រការ ៣ : សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងទេសចរណ៍ ត្រូវទទួល

បន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

ទទួលបន្ទុកកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍

រដ្ឋមន្ត្រីក្រសួងទេសចរណ៍ - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

វេង សេរីវុឌ្ឍ **គាត ឈន់**

* * *

តារាងឧបសម្ព័ន្ធ

បញ្ជីរាយប្រភេទមុខចំណូល នៅក្រសួងទេសចរណ៍

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ការរាយមុខចំណូល(តាមតារាងមាតិកាថវិកា)
				សរុប
២០	០៦	០១	០១	ចំណូលឈ្នួលទីតាំង
២០	០៣	០៤	០១	ចំណូលលក់បណ្ណទស្សនាប្រាសាទ និង ពន្ធរថយន្ត
២១	០៣	០៧		ចំណូលផ្សេង ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួងលេខ ៤៨៥ សហវ.មប្រក

ស្តីពីការបង្កើត និង តែងតាំងភ្នាក់ងារបើក

ផ្តល់សំរាប់បើកបៀវត្សជូនមន្ត្រីរាជការ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត.ប ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្រ្តី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៤ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីភ្នាក់ងារ បើកផ្តល់
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ប្រាក់បៀវត្សមន្រ្តីរាជការនៃក្រសួងទេសចរណ៍ នឹងត្រូវបើកផ្តល់តាមរយៈ រដ្ឋទេយ្យករដែលមានឈ្មោះថា ÷ « ភ្នាក់ងារបើកផ្តល់ »

ប្រការ ២ : កញ្ញា **រស់ ផល្លាប** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់នៅក្រសួងទេសចរណ៍ និង អ្នកស្រី **គី អេងឡាយ** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់ជំនួស ។

ប្រការ ៣ : កញ្ញា **រស់ ផល្លាប** ត្រូវបានអនុញ្ញាតអោយបើកគណនីប្រាក់បញ្ញើនៅរតនាគារជាតិ (ឬរតនាគារខេត្ត–ក្រុង) ដើម្បីទទួលមូលនិធិសំរាប់យកទៅបើកបៀវត្សជូនមន្ត្រីរាជការ ។

ប្រការ ៤ : បែបបទនៃការអនុវត្តន៍បើកផ្តល់បៀវត្សនឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

ប្រការ ៥ : ភ្នាក់ងារបើកផ្តល់ ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស នឹងមូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

ប្រការ ៦ : សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : ខុទ្ទកាល័យ មន្ទីរ នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញកិច្ច រតនាគារជាតិ ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់ និងក្រសួងទេសចរណ៍ ព្រមទាំងកញ្ញា **រស់ ផល្លាប** និងអ្នកស្រី **គី អេងឡាយ** ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា ទៅ ។

ទេសរដ្ឋមន្ត្រី
ទទួលបន្ទុកកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

រដ្ឋមន្ត្រីក្រសួងទេសចរណ៍
ហត្ថលេខា និង ត្រា
ទ៉ែង សារិទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ : ៤៨៦ សហវ .មប្រក

ស្តីពីការតែងតាំងវេជ្ជបណ្ឌិតឲ្យក្របខណ្ឌលនៅក្រសួងទេសចរណ៍

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត.ប ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ១៩៩៣
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជ ក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការអនុវត្តន៏បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម. ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការអនុវត្តន៍ បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០២ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្ដីពីរជ្ជទេយ្យ ចំណូល
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងកញ្ញា **ហុក លាតី** ឋានៈមន្ត្រី តួនាទី ផ្នែកគ្រប់គ្រងចំណូល អោយទទួលការងារបច្ចុប្បន្នជារជ្ជទេយ្យករចំណូលនៅអមក្រសួងទេសចរណ៍។

ប្រការ ២ : ការតែងតាំងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ខែ កក្កដា ឆ្នាំ ១៩៩៦ នេះតទៅ ។

ប្រការ ៣ : សេចក្ដីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ៤ : មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងទេសចរណ៍ ព្រមទាំងកញ្ញា **ហុក លាតី** ត្រូវទទួល បន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
ទទួលបន្ទុកកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

រដ្ឋមន្ត្រីក្រសួងទេសចរណ៍
ហត្ថលេខា និង ត្រា
វ៉េង សេរីវុឌ្ឍ

* * *

៤ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ : ៥៤១ ឧក.ប្រក ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ៅ ស៊ីណាត** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២១៦៨៧៧ ភ.ព ចុះថ្ងៃទី ១១-៤-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ខាន់ខាវ សង្កាត់ ចារាយណ៍ ទីរួមខេត្ត តាកែវ ខេត្តតាកែវ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ម៉ៅ ស៊ីណាត** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយះពេលបី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មាន សំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ិត ប្រាំង

* * *

ប្រកាសលេខ : ៥៦៣ ឧក.ប្រក ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ថាកក្រាល ខេមបូឌា អ៊ិនដាស្ទ្រីស៍ លីមីធីដ THAKRAL CAMBODIA INDUSTRIES LIMITED តំណាងដោយលោក GURMUKH SINGH THAKRAL សញ្ជាតិ សិង្ហបូរី ភេទប្រុស អាយុ ៤៣

ឆ្នាំ អាស័យដ្ឋាន N° ៩០ MEYER ROAD SINGAPORE1543 កាន់លិខិតឆ្លងដែនលេខ 0160639 E ចុះថ្ងៃទី ១៤-៩-៨៨ បង្កើតរោងចក្រតម្លើងទូរទស្សន៍ និងគ្រឿងបរិក្ខារអេឡិចត្រូនិច នាំចេញដែលមានឈ្មោះថា «ថាកក្រាល ខេមបូឌា អ៊ីនដាស្ទ្រីស៍ លីមីធីដ »មានទីតាំង នៅផ្លូវជាតិលេខ ៤ ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល ។

ប្រការ ២ : ការសាងសង់ និង រៀបចំគ្រឿងចក្រត្រូវធ្វើទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានសំរេចក្នុងរយៈពេល ១២ ខែ ដោយរាប់ បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្ម របសរោងចក្រ ។

ប្រការ ៤ : រោងចក្រនេះ ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល « ទូរទស្សន៍, បរិក្ខារអេឡិចត្រូនិច » ទៅតាមគំរូ និងផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹង ប្រការណាមួយដែលបានចែងខាងលើប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

ប្រកាសលេខ : ៥៦៩ ឧក.ប្រក ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៦

ស្តីពីការផ្ទេរកម្មសិទ្ធិ អាគារនិង ដី សម្ព័ន្ធធារីកម្ពុជា

រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញប្រកាសលេខ ២៧២ ផក.ប្រក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការផ្ទេរ អចលនៈទ្រព្យសម្ព័ន្ធចារីកម្ពុជា ។
- បានឃើញប័ណ្ណសំគាលសិទ្ធិកាន់កាប់អចលនៈវត្ថុឃ្លាំងសន្ទឹកថ្នាំតាខ្មៅ លេខ កណ ០០៤១៨៤ ចុះថ្ងៃទី ០៩–៨–៩៦ និង ប័ណ្ណសំគាល់អចលនៈវត្ថុ ទីស្នាក់ការប្រមូលទិញសន្ទឹកថ្នាំ ខេត្តកំពង់ចាម លេខ ក.ច ០០១២៦៨ ចុះថ្ងៃទី ១៧ កក្កដា ឆ្នាំ ១៩៩៦ ។

សម្រេច

ប្រការ ១ : ផ្ទេរកម្មសិទ្ធិអចលនៈទ្រព្យរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលមាន ÷

- ឃ្លាំងសន្ទឹកថ្នាំតាខ្មៅ
- ទីស្នាក់ការប្រមូលទិញសន្ទឹកថ្នាំខេត្តកំពង់ចាម

ដូចមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនៈវត្ថុជូនភ្ជាប់មកជាមួយ ជូនលោក គង់ ទ្រីវ ដើម្បី កាន់កាប់ជាកម្មសិទ្ធិ ។

ប្រការ ២ : លោក គង់ ទ្រីវ ត្រូវទទួលខុសត្រូវរៀបចំបែបបទកាត់ឈ្មោះកម្មសិទ្ធិលើប័ណ្ណ កាន់កាប់អចលនៈវត្ថុដូចមានចែងក្នុងប្រការ ១ ។

ប្រការ ៣ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

៥ - ទីស្តីការរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ១១០ បល.កបទ.សអ.

រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល និង ចុះថ្ងៃទី ៣១-១០-១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើតាមព្រះរាជក្រម លេខ ០២ នស ចុះថ្ងៃទី ២០ ៧-១៩៩៤ ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដែលប្រ កាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម.០១៩៦-១០ ចុះថ្ងៃទី ២៤-០១-១៩៩៦ ។
- បានឃើញប្រកាសលេខ ០៩៥ បល.កបទ.សអ ចុះថ្ងៃទី ០៨-៧-១៩៩៦

សំរេច

ប្រការ ១ : សមាសភាពគណៈកម្មការបច្ចេកទេស កែទំរង់រដ្ឋបាល ប្រចាំក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដែលត្រូវបង្កើតឡើងតាមប្រកាសលេខ ០៩៥ បល..កបទ.សអ ចុះថ្ងៃទី ៨-៧-៩៦ ត្រូវកែប្រែដូចតទៅ :

១-ឯកឧត្តម	**អ៊ុង**	**គឹមអន**	រដ្ឋលេខាធិការ	ប្រធាន
២-ឯកឧត្តម	**ចែម**	**វិឌ្ឍា**	អគ្គលេខាធិការ	អនុប្រធាន
៣-លោក	**ខៀវ**	**កុសលៈ**	ទីប្រឹក្សា	សមាជិក
៤-លោក	**នុត**	**ឌីន**	ទីប្រឹក្សា	សមាជិក
៥-លោក	**សុខ**	**មាឆឿន**	ទីប្រឹក្សា	សមាជិក

៦-លោក ឆោម្រ៉ា ម៉េងហួរ នាយកខុទ្ទកាល័យ សមាជិក

៧-លោក ស៊ុម សួង នាយករដ្ឋបាលទូទៅ សមាជិក

៨-លោក ជាង អេងខួន នាយករងរដ្ឋបាលទូទៅ សមាជិករាយការណ៍

ប្រការ ២ : ខ្លឹមសារឯទៀតនៃប្រកាសលេខ ០៩៥ បល.កបទ.សអ ចុះថ្ងៃទី ០៨-៧-៩៦ ត្រូវរក្សាទុកដដែល ។

ប្រការ ៣ : នាយកខុទ្ទកាល័យរដ្ឋមន្ត្រី រដ្ឋបាលទូទៅ បុគ្គលិក ហិរញ្ញវត្ថុ-គណនេយ្យ គ្រប់នាយកដ្ឋាននិងសាមីខ្លួន ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អ៊ុង ហួត

* * *

៦ - ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៥៨ បន.ប្រក

ស្តីពី

ការតែងតាំងបជ្ជិកាហក:មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តតាកែវ រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦-២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ស្តីពីបង្កើត ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ និង ប្រកាសអោយប្រើ នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញប្រកាសលេខ ០៨២ ប្រក.បទ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំរចនាសម្ព័ន្ធ មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខ្សែរយៈបណ្តោយគ្រប់ ខេត្ត-ក្រុង
- បានឃើញលិខិតស្នើសុំតែងតាំងលេខ ២៣៥ បទ.តក ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៦ របស់មន្ទីរប.ទ ខេត្តតាកែវ
- ពិនិត្យសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងអ្នកស្រី **ម៉ម សារី** ជាបរិគ្គាហកៈរងមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តតាកែវ ។

ប្រការ ២ : បរិគ្គាហកៈរងមានភារកិច្ចរួមសហការ និង ទទួលខុសត្រូវលើការងារសេវាកម្ម អាជីវកម្ម ប្រៃសណីយ៍ និងទូរគមនាគមន៍ទូទាំងខេត្ត-ស្រុក ជូនមុខអោយក្រសួង ។

ប្រការ ៣ : ខុទ្ទកាល័យ, អធិការដ្ឋាន , នាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញកិច្ច មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តតាកែវ និងសាម៉ីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍ តាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ស៊ូ ឃុន

* * *

៧ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ២៩៧ ពណ. បល. ប្រក

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ដែលប្រកាសអោយប្រើដោយព្រះរាជ ក្រម លេខ នស/រកម /០១៩៦ /១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- យោងការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ ១ : បង្កើតការិយាល័យប្រព័ន្ធអនុគ្រោះទូទៅ (G S P)ចំណុះនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស នៃក្រសួងពាណិជ្ជកម្ម ។

ប្រការ ២ : ភារកិច្ចរបស់ ការិយាល័យប្រព័ន្ធអនុគ្រោះទូទៅ រួមមាន :

- ផ្សព្វផ្សាយពត៌មានស្តីអំពី ប្រព័ន្ធអនុគ្រោះអន្តរជាតិ ជូនដល់ផលិតករ ពាណិជ្ជករ និង អ្នកវិនិយោគទុន ព្រមទាំងអត្ថប្រយោជន៍នៃប្រព័ន្ធនេះ ដើម្បីជំរុញការនាំចេញ ដែលរួមមានផ្នែក កសិផល និង ជលផល ។
- ទទួលពត៌មានពី (UNCTAD United Nation Conference on Trade and Deve lopment) ស្តីអំពីការផ្លាស់ប្តូរ និងការកែប្រែនៃប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។
- ចេញនូវវិញ្ញាបនប័ត្រ បញ្ជាក់ប្រភពទំនិញ (C/O From A និង C/O) ជូនដល់ផលិតករ ពាណិជ្ជករ និងអ្នកវិនិយោគទុន ។
- ពិនិត្យអង្កេតលើវិញ្ញាបនប័ត្រប្រភពទំនិញ ស្ថិតិ ។

ប្រការ ៣ : ការិយាល័យប្រព័ន្ធអនុគ្រោះទូទៅ ដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានជំនួយការ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសត្រូវអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

* * *

៨ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាស លេខ ៨២១ អយក.ប្រក

ស្តីពីការបើក « អនុវិទ្យាល័យ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ »

ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ ខែ មេសា ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត ១ កំរិត ២ ។
- យោងលិខិតសំណើរបស់ប្រធានកិត្តិយស និងប្រធានសាងសង់នៃ អនុវិទ្យាល័យសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ដោយមានយោបល់ឯកភាពពីប្រធានមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តព្រៃវែង ។
- តាមព្រះរាជចំណាររយល់ព្រមរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង បើកអនុវិទ្យាល័យ ដែលមានឈ្មោះថា អនុវិទ្យាល័យ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ជាង

ដែក ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ចាប់ពីឆ្នាំសិក្សា ១៩៩៦ - ៩៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេង ៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក នាយករង នៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក នាយករង នៃអនុវិទ្យាល័យ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញវត្ថុ នៃ ក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តព្រៃវែង និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀង ៗ ខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១២០០ រៀល